


Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥២

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបន្តស្តាប់សក្ខីកម្មរបស់សាក្សីដែលធ្លាប់បានធ្វើការនៅមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីដំបូងគេ គឺលោក **តយ តេង** ដែលភិនភាគរូបរាង និងសំឡេងរបស់គាត់ត្រូវបានបំលែងដោយស្ថិតនៅក្រោមវិធានការណ៍ការពារ បានបញ្ចប់សក្ខីកម្មរបស់គាត់ដែលបានបន្តតាំងពីសប្តាហ៍មុនមកម្ល៉េះ ពាក់ព័ន្ធនឹងការងាររបស់គាត់ជាអ្នកយាមនៅមន្ទីរសន្តិសុខ ស-២១ និងនៅជើងឯក។ សាក្សីបន្ទាប់ឈ្មោះលោក **ឡាច មាន** បានផ្តល់សក្ខីកម្មស្តីពីតួនាទីរបស់គាត់ជាអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខ ស-២១។ សាក្សីចុងក្រោយ គឺលោក **ប្រាក់ ខន** បានផ្តល់សក្ខីកម្មផងដែរ អំពីការសួរយកចម្លើយ និងការធ្វើទារុណកម្មដែលគាត់បានប្រព្រឹត្ត ក្នុងពេលដែលបានធ្វើការនៅមន្ទីរសន្តិសុខ ស-២១។ នៅពេលព្រឹកថ្ងៃពុធ ជនជាប់ចោទលោក **នួន ជា** បានលះបង់ការនៅស្ងៀមរបស់គាត់ ដើម្បីផ្តល់សក្ខីកម្មស្តីពីការវាទទីទឹកដីរបស់ប្រទេសវៀតណាម ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីការធ្លាប់បានចោទសំណួរទៅកាន់សាក្សីជំនាញមួយចំនួនមក ទង្វើបែបនេះ គឺជាលើកទីមួយហើយដែលគាត់បានផ្លាស់ប្តូរជំហរនៅស្ងៀមរបស់គាត់ ក្នុងសំណុំរឿង០០២ វគ្គ២ នេះ ។[1] ក្នុងសប្តាហ៍នេះផងដែរ អង្គជំនុំជម្រះសាលាដំបូង

---

[1] ជនជាប់ចោទលោក **នួន ជា** កាលពីពេលមុនធ្លាប់បានលះបង់ការនៅស្ងៀមរបស់គាត់ក្នុងសំណុំរឿង០០២ វគ្គ២ នេះ ដើម្បីចោទសំណួរទៅកាន់សាក្សីជំនាញលោកស្រី **អេលេហ្សាប៊ែត បេកឃើរ** (Elizabeth Bechker) និងលោក **អាឡិចសែនឌើរ ហ៊ីនតុន** (Alexander Hinton)។ លោក **នួន ជា** បានចោទសួរអ្នកកាសែតលោកស្រី **បេកឃើរ** (Bechker) ចំនួនពីរសំណួរស្តីពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅអំឡុងពេលមុនឆ្នាំ១៩៧៥។ សម្រាប់សេចក្តីសង្ខេបនៃព្រឹត្តិការណ៍នេះ *សូមមើល* របាយការណ៍ប្រចាំសប្តាហ៍របស់អ្នក

បានធ្វើការដោះស្រាយសាជាថ្មីម្តងទៀត ជុំវិញបញ្ហានៃភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម ហើយរួមទាំងបានធ្វើការពិភាក្សាលើការកំណត់និយមន័យផ្លូវច្បាប់របស់ពាក្យទារុណកម្ម និងបញ្ហានៃការបកប្រែភាសាផងដែរ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លេណា ហារីស ពោមីរ៉យ (Lena Harris-Pomeroy), ម៉ាលេនី ហៃដ៍ (Melanie Hyde), គុំ សុម៉ាលី, នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), នំ វិសុទ្ធ, តាយលីណា និង ធន ស្ថាពរ ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

ឃ្លាំមើលសវនាការសាលាក្តីខ្មែរក្នុងសំណុំរឿង០០២ វគ្គ២ លេខ៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥ (ចុះថ្ងៃទី៩ ដល់ទី១២ ខែកុម្ភៈ ឆ្នាំ២០១៥)។ លោក **នួន ជា** ក៏បានចោទសំណួរទៅកាន់នរវិទូលោក **ហ៊ីនថុន** (Hinton) ពាក់ព័ន្ធនឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅមុនឆ្នាំ១៩៧៥ និងគោលនយោបាយការបរទេសរបស់ប្រទេសវៀតណាម ផងដែរ ដែលសេចក្តីសង្ខេបទាំងនេះ មាននៅក្នុងរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមក្នុងសំណុំរឿង០០២ វគ្គ២ លេខ៤៧ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤៤ (ចុះថ្ងៃទី១៤ ដល់ទី១៧ ខែមីនា ឆ្នាំ២០១៦)។